# បឹងព្រែកល្ពៅ

**A1, A3 & A4i**



**ខេត្ត** : តាកែវ

**ស្រុក** : បូរីជលសារ និង កោះអណ្ដែត

**ផ្ទៃដី ( ហិកតា)** : ៩.២៧៦

**រយៈកំពស់ ( ម៉ែត្រ)** : ៤ ដល់ ៥

**កូអរដោនេចំណុចកណ្ដាល** : ១០°៤៣´ ជ ១០៥° ០២´ ក

## ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ រួមមានតំបន់វាលស្មៅលិចទឹកតាមរដូវកាលស្ថិតនៅក្នុងតំបន់វាលទំនាបនៃទន្លេបាសាក់ ដែលបង្កើតបានជាតំបន់ដែលមានទីជំរកធម្មជាតិយ៉ាងធំបំផុតដែលនៅសេសសល់តាមដីសណ្ដរទន្លេមេគង្គ ។ តំបន់នេះមានព្រំទល់ជាប់នឹងប្រទេសវៀតណាមនៅប៉ែកខាងត្បូង និង ខាងកើតដែលនៅទីនោះប្រភេទទីជំរកធម្មជាតិត្រូវបានប្រែក្លាយស្ទើរតែទាំងអស់ទៅជាតំបន់កសិកម្ម ។ តំបន់ IBA នេះត្រូវលិចទឹកជារៀងរាល់ឆ្នាំពីបីទៅបួនខែ និង នៅក្នុងអំឡុងពេលនោះមានរុក្ខជាតិដុះក្រាលគ្របលើផ្ទៃទឹករួមមានប្រហែល៣០ប្រភេទ ។ នៅក្នុងរដូវប្រាំង ចាប់ពីខែ ធ្នូ រហូតដល់ខែ ឧសភា តំបន់នេះបានផ្ដល់កន្លែងរកចំណីយ៉ាងធំបំផុតសម្រាប់សត្វក្រៀលនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីអាងត្រពាំងថ្ម ។ តំបន់នេះក៏បានទ្រទ្រង់ផងដែរនូវប្រភេទសត្វស្លាបទទួលរងការគំរាមកំហែង និង ជិតរងគ្រោះក្នុងពិភពលោកដែលគួរឱ្យកត់សំគាល់នោះ គឺសត្វខ្សឹប ។ នៅឆ្នាំ ២០០២ តំបន់នេះត្រូវបានដាក់ស្នើសុំជាតំបន់គ្រប់គ្រង និង អភិរក្សដែនបំរុងសត្វក្រៀលដោយនាយកដ្ឋានរុក្ខា-ប្រមាញ់ ។

## ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA | |
|---|---|---|---|---|
| ក្រៀល | Sarus Crane | *Grus antigone* | A1 | A4i |
| ខ្សឹប | Bengal Florican | *Houbaropsis bengalensis* | A1 | |
| ទុងប្រផេះ | Spot-billed Pelican | *Pelecanus philippensis* | A1 | |
| រនាលពណ៌ | Painted Stork | *Mycteria leucocephala* | A1 | |
| ស្នោញ | Darter | *Anhinga melanogaster* | A1 | |

## ប្រភេទសត្វប្រមូលផ្ដុំក្នុងតំបន់មួយជាក់លាក់

មានសត្វស្លាបមួយប្រភេទរស់ក្នុងប្រភេទព្រៃរបោះ និង មួយប្រភេទរស់នៅក្នុងតំបន់ទំនាបវាលស្មៅ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

### ការគំរាមកំហែងលើជីវៈចំរុះ

ការគំរាមកំហែងដែលកើតមានក្នុងតំបន់នេះ គឺការប្រើប្រាស់ថ្នាំពុល ដើម្បីសំលាប់សត្វស្លាបទឹកដែលជាសកម្មភាពធ្វើឱ្យប៉ះពាល់ដល់ក្រៀលផងដែរ ។ សកម្មភាពនេសាទដែលធ្វើឡើងនៅគ្រប់ទីកន្លែងក្នុងតំបន់នេះ គឺជាប្រភពមួយផងដែរនៃការគំរាមកំហែង ជាពិសេសការនេសាទដោយធ្វើការបូមបាចទឹកចេញពីតំបន់ដីសើមដើម្បីចាប់ត្រី ។ ការគំរាមកំហែងធំបំផុតក្នុងតំបន់

នេះអាចជាការពង្រីកដីកសិកម្ម និង បច្ចុប្បន្ន មានផ្ទៃដីយ៉ាងធំនៃតំបន់វាលទំនាបរបស់ទន្លេបាសាក់នៅក្នុងតំបន់ IBA នេះត្រូវបានប្រែក្លាយជាតំបន់កសិកម្មដំណាំស្រូវដោយប្រើប្រាស់ទឹកសម្រាប់ធ្វើការស្រោចស្រព ហើយនៅមានគំរោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្របន្ថែមទៀតនៅក្នុងតំបន់នេះនាពេលអនាគត ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ការរកចំណីរបស់សត្វក្រៀល ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានការសម្របសម្រួលជាបន្តបន្ទាប់ និង តំលៃសេដ្ឋកិច្ចសង្គមនៃប្រភេទទីជំរកធម្មជាតិនៅក្នុងតំបន់បានធ្វើឱ្យផែនការអភិវឌ្ឍន៍ទាំងនោះត្រូវបានកែប្រែ ដើម្បីកាត់បន្ថយផលប៉ះពាល់លើតំបន់ IBA នេះ ។

**អនុសាសន៍**

វិធានការទាំងឡាយគួរតែត្រូវយកមកអនុវត្តឱ្យបានឆាប់រហ័ស ដើម្បីដាក់តំបន់ស្នូលនេះជាតំបន់អភិរក្សមួយដូចតំបន់អាងត្រពាំងថ្ម (KH001) ។

ការអនុវត្តន៍ច្បាប់គួរតែធ្វើឡើងឱ្យបានឆាប់រហ័ស ដោយផ្តោតលើការប្រមាញ់សត្វស្លាបទឹក និង សកម្មភាពនេសាទខុសច្បាប់ទាំងឡាយ ។

យុទ្ធនាការអប់រំផ្សព្វផ្សាយចំណេះដឹងគួរតែធ្វើឡើងនៅតាមភូមិនានាដែលនៅជុំវិញតំបន់នោះ ដើម្បីឱ្យមានការគាំទ្រពីប្រជាជនមូលដ្ឋានសម្រាប់ការអភិរក្សសត្វក្រៀល ។

ការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ឬ កសិកម្មនៅក្នុងតំបន់មិនគួរអនុវត្តដោយគ្មានធ្វើការវាយតំលៃផលប៉ះពាល់បរិស្ថាននោះទេ និង ការយល់ដឹងឱ្យបានស៊ីជំរៅនៃប្រសិទ្ធភាពដែលមានសក្តានុពលលើតំបន់ដីសើមធម្មជាតិ ដែលក្រៀលមានទំនាក់ទំនងជាមួយ ។

**ឯកសារយោង**


Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.

Seng Kim Hout (2001) *Rapid survey of Takeo province, 8-10 November 2001*. Unpublished report to the Department of Forestry and Wildlife, the Department of Nature Conservation and Protection, the Wildlife Conservation Society Cambodia Program and the BirdLife International Vietnam Programme.

Seng Kim Hout, Pech Bunnat, Song Chansocheat, Say Sayoeun and Tordoff, A. W. (2002) *A rapid field survey of three wetland sites in Takeo province, Cambodia*. Unpublished report to the Department of Forestry and Wildlife, the Department of Nature Conservation and Protection, the Wildlife Conservation Society Cambodia Program and the BirdLife International Vietnam Programme.

Tran Triet *et al.* (2000) *Aerial survey of grasslands in Takeo and Kampot provinces*. Unpublished report to the International Crane Foundation.